ឥតគ្គបំប៉ងស្តីពី
ការសិក្សាបែបគម្រោង

Project based Learning Training

បង្រៀនដោយ៖ លោក អ៊ុល រុន

ទីប្រឹក្សាអប់រំជាន់ខ្ពស់ និងជាប្រធានប្រតិបត្តិកម្មវិធីសាលារៀនជំនាន់ថ្មី នៃអង្គការខេប

ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១



គោលបំណង

សិក្ខាកាមដែលជាគ្រូបឋមសិក្សា ឬមធ្យមសិក្សាទាំងអស់នឹងអាចដឹកនាំការបង្រៀនប្រកបដោយប្រសិទ្ធភាព និងសប្បាយរីករាយដោយឱ្យសិស្សអនុវត្តការងារគម្រោង តាមប្រធានបទពាក់ព័ន្ធ ដើម្បីបង្កើតនូវផលិតផលចុងក្រោយមួយដូចជា ខិតបណ្ណកម្រងរូបភាព បទបង្ហាញ ក្រាហ្វិក របាយការណ៍ ចងក្រងឯកសារ។ល។ ហើយសមិទ្ធផលនៃការអនុវត្តគម្រោងរបស់ពួកគេនឹងត្រូវបានធ្វើបទបង្ហាញដល់អ្នកពាក់ព័ន្ធ។ (ទំព័រទី៣)

លទ្ធផលពីចក្រ



គ្រូបង្រៀនម្នាក់ៗនឹង

- ✓ មានផែនការការសិក្សាបែបគម្រោង។
- ✓ អនុវត្តការងារគម្រោងរបស់ខ្លួន។
- ✓ អភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនលើបច្ចេកទេសបង្រៀន។
- ✓ មានបំណិនក្នុងការប្រើប្រាស់ឧបករណ៍ ICT ដែលមានស្រាប់ក្នុងសាលារៀនរបស់ខ្លួន។ (ទំព័រទី៣)

លទ្ធផលរំពឹងទុក



សិស្សម្នាក់ៗនឹង

- ✓ សប្បាយរីករាយក្នុងការសិក្សានិងទទួលបានការសិក្សាពិតប្រាកដ។
- ✓ មានជំនាញសិក្សាស្រាវជ្រាវនិងធ្វើបទបង្ហាញ។
- ✓ អភិវឌ្ឍបំណិនសម្បទាទូទៅនិងមានចរិយាសម្បទាសមស្រប។
- ✓ អនុវត្តការប្រើប្រាស់ឧបករណ៍ ICT។ (ទំព័រទី៣)

តើរៀនដើម្បីអ្វី?

ដើម្បីប្រឡងនិងបន្តការសិក្សា

សិស្សរៀនបាន ៖

- ✓ខ្លឹមសារ
- ✓ទ្រឹស្តី
- ✓រូបមន្ត




ដើម្បីជីវិតរស់នៅនិងការងារ

សិស្សរៀនបាន ៖

- ✓ ការប្រើប្រាស់ចំណេះដឹងក្នុងការរស់នៅនិងអភិវឌ្ឍបំណិនចាំបាច់ក្នុងការរស់នៅនិងការងារ។
- ✓ ការស្វែងយល់ពីបរិស្ថានជុំវិញខ្លួន រួចសាទរនឹងវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់និងការអនុវត្តល្អរបស់ខ្លួន ហើយកែលម្អចំណុចខ្វះខាត។
- ✓ បង្កើតឱ្យមានកិច្ចសហការនិងសាមគ្គីល្អនៅក្នុងមូលដ្ឋាន។

(ទំព័រទី៤)

តើអ្វីជាការរៀនពិតប្រាកដ?



សមិទ្ធផលដែលសិស្សអាចឆ្លាបាន

- ✓ **វិជ្ជាសម្បទា ៖** ប្រធានបទជាក់លាក់ដែលគេបានអនុវត្ត ឬធ្វើការស្រាវជ្រាវដោយប្រើចំណេះដឹងគ្រប់មុខវិជ្ជាដែលគេបានរៀនក្នុងថ្នាក់រៀនក្រៅថ្នាក់រៀន (កុំព្យូទ័រ ថាប់ប្លែត ។ល។)។
- ✓ **បំណិនសម្បទា ៖** ការប្រាស្រ័យទាក់ទង អន្តរបុគ្គល ការគិតដោយវិភាគ ការសម្រេចចិត្ត ការដោះស្រាយបញ្ហា ការបង្ហាញហេតុផលនិងភស្តុតាង ការធ្វើផែនការ ការសហការ ។ល។
- ✓ **ចរិយាសម្បទា ៖** ទំនុកចិត្តលើខ្លួនឯង ការឱ្យតម្លៃខ្លួនឯងនិងអ្នកដទៃ អធ្យាស្រ័យល្អ ភាពអំណត់ ភាពស្មោះត្រង់ ការទទួលខុសត្រូវនិងឥរិយាថវិជ្ជមាន ។ល។ (ទំព័រទី ៤)













តើសិស្សអភិវឌ្ឍបានអ្វីខ្លះ ?


សូមទស្សនាវីដេអូអំពីសមិទ្ធផលរបស់សិស្ស

- ប្រធានបទ៖ ជំងឺគ្រុនឈាម https://www.youtube.com/watch?v=nXR38gOJcaY&feature=share&fbclid=IwAR2Z9ELdnBbRDw7EHs7i5lyl1ltZ9HKSYrMjwmv-UJeSZL4LXH1IJ-XNvlc
- ប្រធានបទ៖ ជំងឺStroke https://www.youtube.com/watch?v=1w9pu3daF6I&feature=youtu.be

សកម្មភាពក្នុងវីដេអូ នាំទៅរក ការបង្កើតផលិតផល "ចំណេះដឹង"

- ផលិតផលសិក្សាចេញពីសកម្មភាពក្នុងវីដេអូមានលក្ខណៈដូចខាងក្រោម៖
  - សិស្សសហការគ្នាដើម្បីរៀនពីគ្នាទៅវិញទៅមក
  - ពួកគេបង្កើត" ចំណេះដឹងថ្មី" ប្លែកទៅតាមសមត្ថភាពរបស់ក្រុមសិស្ស
  - ពួកគេពង្រឹងចំណេះដឹងមុន ៗ ផ្អែកលើអ្វីដែលពួកគេស្រាវជ្រាវឃើញ









តើគម្រោងជាអ្វី?

តើការសិក្សាបែបគម្រោងជាអ្វី?

ការសិក្សាបែបគម្រោងជាបទពិសោធន៍នៃការសិក្សាមួយ ដែលផ្តល់ឱ្យសិស្ស នូវឱកាសដើម្បីសំយោគចំណេះដឹងពីផ្នែកផ្សេងៗនៃការសិក្សា រួចអនុវត្តវាទៅក្នុងស្ថានភាពរស់នៅប្រចាំថ្ងៃ ឬការស្រាវជ្រាវប្រកបដោយការវិភាគនិងច្នៃប្រឌិត។

ដំណើរការនេះជួយលើកកម្ពស់ចំណេះដឹងដល់សិស្សនិងអាចឱ្យពួកគេទទួលបានបំណិនជាច្រើនដូចជា ៖ បំណិនសហការ បំណិនប្រាស្រ័យទាក់ទងនិងការរៀនដោយម្ចាស់ការ ព្រមទាំងរៀបចំពួកគេសម្រាប់ការរៀនមួយជីវិតនិងត្រៀមខ្លួនក្នុងការប្រឈមនឹងឧបសគ្គនាពេលអនាគត។ (ទំព័រទី ៩)

ការសង់អាគារដោយប្រើបំពង់បឺត

- https://youtu.be/CbzJWTqaY5g

ការអនុវត្តការងារគម្រោង

១. មុនពេលសាងសង់ = ការធ្វើផែនការ

២. កំពុងសាងសង់ = ការអនុវត្តផែនការ

៣. ក្រោយពេលសាងសង់ = ការវាយតម្លៃផែនការ

តើការងារគម្រោងជាអ្វី?



លទ្ធផលសិក្សាតាមរយៈការចាត់តួនាទី

យើងទទួលបានលទ្ធផលសិក្សាចម្បងៗមួយចំនួនដូចជា ៖ ការអនុវត្ត ចំណេះដឹង ការប្រាស្រ័យទាក់ទង កិច្ចសហការ ភាពច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហា និងការរៀនដោយម្ចាស់ការ។ នៅពេលសិស្សធ្វើការជាក្រុម ពួកគេនឹងរៀនដោយម្ចាស់ការ តាមរយៈការឆ្ពុះបញ្ចាំងផ្ទាល់ខ្លួននិងវាយតម្លៃការរីកចម្រើនការងារផ្ទាល់ខ្លួនរបស់ពួកគេ។ លទ្ធផលនៃការសិក្សាទាំងនេះនឹងកើតឡើង ដោយមានអន្តរកម្មរវាងផ្នែក ឬមុខវិជ្ជាជាច្រើន មិនមែនផ្តោតលើតែផ្នែកមួយ ឬមុខវិជ្ជាមួយឡើយ។

(ទំព័រទី៩ & ១០)

សូមមើលឧទាហរណ៍ខាងក្រោមពីរបៀបដែលសាលារៀនជំនាន់ថ្មីដំរុញការសិក្សាបែបគម្រោង. . .

https://www.youtube.com/watch ?v=Q41GBfq3qq8&feature=youtu.be

ការឆ្លុះបញ្ចាំងពីវីដេអូ

- តើសិស្សអភិវឌ្ឍបានអ្វីខ្លះ?
- តើអ្នកអាចបង្រៀនតាមបែបនេះ ពាក់ព័ន្ធនឹងមុខវិជ្ជារបស់អ្នកបានឬទេ?

ប្រភេទនៃការសិក្សា បែបគម្រោងដែលគ្រូអាចរៀបចំបាន




(ទំព័រទី១០ &១១)

អ្វីដែលមានស្រាប់



- ✓ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ (ប្រាសាទដែលមានក្នុងមូលដ្ឋាន ទីកន្លែងប្រវត្តិសាស្ត្រ ឈ្មោះភូមិឬក៏ដកស្រង់ប្រធានបទក្នុងកម្មវិធីសិក្សា...) អាចធ្វើជាក្តីបមុខវិជ្ជា។
- ✓ វប្បធម៌ ប្រពៃណី (រចាំ សិល្បៈ បុណ្យទាន ឬក៏ដកស្រង់ប្រធានបទក្នុងកម្មវិធីសិក្សា...)។
- ✓ រៀបចំពិសោធន៍វិទ្យាសាស្ត្រ (គីមីវិទ្យា រូបវិទ្យា ...) អាចធ្វើជាក្តីបមុខវិជ្ជា។



អ្វីដែលមានស្រាប់

- ✓ មេរៀនតាមមុខវិជ្ជាដែលមាននៅក្នុងកម្មវិធីសិក្សា (ភាសារ ខ្មែរ/អង់គ្លេស ៖ អានអត្ថបទដោយប្រើល្បឿនបានត្រឹមត្រូវ ការពន្យល់ពាក្យពិបាក ការរកវេរចនសព្ទ...) អាចធ្វើជាក្តីបមុខវិជ្ជា។
- ✓ របកគំហើញវិទ្យាសាស្ត្រ (និយាយពីភព និយាយពីការវិវឌ្ឍមនុស្ស សត្វ ជំងឺ ប្រព័ន្ធគ្រោងឆ្អឹងមនុស្ស សូរ្យគ្រាស ឬក៏ដកស្រង់ប្រធានបទក្នុងកម្មវិធីសិក្សា...)
- ✓ សូមមើលគំរូឧទាហរណ៍ប្រធានបទតាមមុខវិជ្ជានីមួយៗ របស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ព្រឹត្តិការណ៍ “បំណងប្រាថ្នា” **ទំព័រទី ៤** ក្នុងឧបសម្ព័ន្ធបន្ថែម។



ហេតុការពិត ឬបញ្ហាជួបប្រទះប្រចាំថ្ងៃ

- ✓ សង្គម (អំពើហិង្សាក្នុងគ្រួសារ ចំណាកស្រុក សុវត្ថិភាពចរាចរ ឥទ្ធិពលគ្រឿងញៀន ការរំលោភសិទ្ធកុមារ...)។
- ✓ សុខភាព (ការឆ្លងនិងបង្ការជំងឺគ្រុនឈាម ការឆ្លងនិងបង្ការជំងឺគ្រុនផ្តាសាយបក្សី អនាម័យខ្លួនប្រាណ ការប្រើប្រាស់គ្រឿងញៀន អាហារសុខភាព...)។
- ✓ វិស័យអប់រំ (មូលហេតុសិស្សខ្សោយអំណាននិងវិធីពង្រឹងអំណាន ផលប្រយោជន៍នៃការអានសៀវភៅ ផលប្រយោជន៍នៃការសិក្សា មូលហេតុនៃការអវត្តមានរបស់សិស្ស...)។






ប្រភេទគម្រោងចំនួន៧ ដែលកំណត់ដោយក្រសួងអយក សម្រាប់ព្រឹត្តិការណ៍ "បំណងប្រាថ្នា"

1. គម្រោងដោយផ្តោតលើការតែងនិពន្ធ
2. គម្រោងដោយការប្រមូលព័ត៌មាននិងទិន្នន័យ
3. គម្រោងដោយការសង្កេត
4. គម្រោងផ្សាភ្ជាប់ទ្រឹស្តីជាមួយពិភពពិតនិងជាក់ស្តែង
5. ការបង្កើតគម្រោងដោយការពិសោធន៍វិទ្យាសាស្ត្រ
6. គម្រោងផលិតជាវត្ថុគំរូ (Prototype) ឬរចនាបច្ចេកវិទ្យា
7. គម្រោងដោះស្រាយបញ្ហានិងការបង្កើតកិច្ចពិភាក្សា

*សូមមើលការពន្យល់លម្អិត អមដោយឧទាហរណ៍ប្រធានបទគម្រោងតាមមុខវិជ្ជា**ទំព័រទី៩-១៤** នៃឯកសារក្រសួងអយកសម្រាប់ព្រឹត្តិការណ៍ "បំណងប្រាថ្នា" ក្នុងឧបសម្ព័ន្ធបន្ថែម*

សាលារៀនធ្វើការប្រជុំតម្រង់ទិសគ្រូបង្រៀនអំពីការសិក្សាបែបគម្រោង និងជំរុញការចូលរួមតាមរយៈ**ទម្រង់បង្ហាញពីចំណាប់អារម្មណ៍គ្រូបង្រៀន** ក្នុងឧបសម្ព័ន្ធទី២ **ទំព័រទី៣២**

ការវាយតម្លៃការងារគម្រោងរបស់សិស្ស


ក. ការទទួលបានព័ត៌មាននិងការប្រមូលទិន្នន័យរបស់សិស្ស ពេលកំពុងដំណើរការ។ (ណែនាំឧបករណ៍ពិនិត្យតាមដានការងារគម្រោងក្នុងឧបសម្ព័ន្ធទី៣ ទំព័រទី៣៤)

ខ. ការវាយតម្លៃផលិតផលចុងក្រោយ ឬការប្រតិបត្តិរបស់សិស្សនៅពេលដែលគេធ្វើបទបង្ហាញនិងធ្វើការបកស្រាយ។ (ណែនាំឧបករណ៍វាយតម្លៃការធ្វើបទបង្ហាញលទ្ធផលការងារគម្រោង ក្នុងឧបសម្ព័ន្ធទី៤ ទំព័រទី៣៧)



(ទំព័រទី១២)


បំណិនដែនការគិត



(ទំព័រទី១៤ &១៥)

ធាតុសំខាន់ៗនៃផែនការគម្រោង


- ✓ ការកំណត់គោលបំណង/លទ្ធផលចុងក្រោយ (គិតមុនគេ)
- ✓ សកម្មភាព/រយៈពេល/ធនធាន (លម្អិតសកម្មភាពជាដំណាក់ៗ)
- ✓ ការវាយតម្លៃ (ធៀបទៅនឹងគោលបំណង)



(ទំព័រទី១៥,១៦,១៧ &១៨)

ការអនុវត្ត៖ ជ្រើសរើសប្រធានបទបង្កើតគម្រោង និងមើលគំរូផែនការគម្រោង ក្នុងឧបសម្ព័ន្ធ១ក ទំព័រទី១៩, ១ខ ទំព័រទី២៤ និង ១គទំព័រទី២៨

គោលការណ៍នៃការស្រាវជ្រាវ



ប្រសិនបើមិនមានលទ្ធផល

ក. កំណត់ពីប្រធានបទ ឬ បញ្ហាដែលត្រូវដោះស្រាយ

ខ. កំណត់ពីអ្វីដែលអ្នកដឹង ឬ អ្វីដែលត្រូវរៀន

គ. ស្រាវជ្រាវពីប្រធានបទ ឬ ធ្លើយទៅនឹងសំណួរដែលអ្នកមាន

ឃ. ធ្វើការទស្សទាយ ដោយបង្កើតជាសម្មតកម្ម

ង. រៀបចំការពិសោធន៍ (បញ្ជាក់ពីសម្មតិកម្ម)

ច. ប្រមូលទិន្នន័យតាមរយៈការសង្កេត និង ប្រើរង្វាស់ត្រឹមត្រូវ

ជ. ទាញសេចក្តីសន្និដ្ឋាន និង ចងក្រងស្នាដៃ រួចចែករំលែកជាមួយអ្នកដទៃ



ការប្រៀបធៀបរវាងការសិក្សានិងការធ្វើទឹកក្រឡុក









បំប្លែង

សូមអរគុណ